**សេចក្តីជូនដំណឹងដល់សារព័ត៌មានរបស់អង្គការ Global Witness**

**ថ្ងៃទី 23 ខែ តុលា ឆ្នាំ 2017**

# ឧស្សាហកម្មចិនចាត់វិធានការដោយរឹងមាំដោយឥតកោតក្រែងដើម្បីលែលកចំពោះការដណ្តើមដីធ្លី ដោយផ្តើមដាក់ដំណើរការគោលការណ៍ណែនាំថ្មីលើដំណាំកៅស៊ូ

គោលការណ៍ណែនាំរបស់ឧស្សាហកម្មកៅស៊ូចិនថ្មី អាចនឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការដោះស្រាយការដណ្តើមយកដីធ្លី និងការកាប់បំផ្លាញព្រៃឈើនៅពាសពេញទូទាំងតំបន់មេគង្គ យោងតាមក្រុមអង្គការមិនមែនរដ្ឋាភិបាលឈ្មោះថា Global Witness ។ គោលការណ៍ណែនាំនេះ ដែលត្រូវបានចាប់ផ្តើមដំណើរការនៅថ្ងៃនេះនៅសន្និសីទអន្តររដ្ឋាភិបាលក្នុងទីក្រុង Ho Chi Minh ប្រទេសវៀតណាម មានការបោះជំហានទៅមុខបំផុតនៅក្នុងការលើកថ្លែងនូវហានិភ័យសង្គម និងបរិស្ថាន សម្រាប់ក្រុមហ៊ុនដែលជាប់ទាក់ទងជាមួយនឹងចំការកៅស៊ូទ្រង់ទ្រាយធំទាំងឡាយ នៅទូទាំងពិភពលោក។

Ali Hines នៃក្រុមដីធ្លីរបស់អង្គការ Global Witness បានមានប្រសាសន៍ថា ៖ “គោលការណ៍ណែនាំនានាបានចេញនៅចំពេលដ៏សំខាន់សម្រាប់ឧស្សាហកម្មកៅស៊ូ ។ ទសវត្សរ៍ចុងក្រោយបានមើលឃើញនូវក្រុមហ៊ុនដែលគ្មានគោលការណ៍សីលធ៌មបង្ខំប្រជាជនយ៉ាងឆាប់រហ័សឲ្យចេញពីដីធ្លីរបស់ពួកគេ ហើយបំផ្លាញព្រៃសម្ខាន់ៗ ក្នុងដំណើររបស់ពួកគេក្នុងការពង្រីកប្រតិបត្តិការនានានោះ ។ ប៉ុន្តែឧស្សាហកម្មនេះ មិនត្រូវការចាំបាច់ប្រែប្រឡាក់ខូចឈ្មោះដោយហានិភ័យទាំងនេះឡើយ ។ ក្នុងនាមជាប្រទេសប្រើប្រាស់មួយ ក្នុងចំណោមអតិថិជនអ្នកប្រើប្រាស់ និងប្រទេស ផលិតកៅស៊ូធម្មជាតិកំពូល ឧស្សាហកម្មចិនអាចបង្ហាញនូវភាពជាអ្នកដឹកនាំពិតប្រាកក្នុងការទទួលស្គាល់និងកាត់បន្ថយនូវហានិភ័យនៃខ្សែសង្វាក់ផ្គត់ផ្គង់ ការពារព្រៃឈើ និងសិទ្ធិនៃសហគមន៍ជនជាតិដើមភាគតិចដូចដែលបានប្រកាសចែងនៅក្នុងគោលការណ៍ណែនាំថ្មីទាំងឡាយនោះ”។

គោលការណ៍ណែនាំនៃប្រទេសចិនសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃកៅស៊ូធម្មជាតិ[1] (The Chinese Guidelines for Sustainable Development of Natural Rubber) ត្រូវបានដាក់ឲ្យចាប់ដំណើរការដោយសភាពាណិជ្ជកម្មចិន នៃអ្នកនាំចូល អ្នកនាំចេញលោហ: រ៉ែខនិជ និងធាតុគីមី (CCCMC) ដែលគ្រប់គ្រងមើលការខុសត្រូវដោយក្រសួងពាណិជ្ជកម្ម ។

គោលការណ៍ណែនាំទាំងឡាយនេះ ត្រូវបានពង្រាងដោយផ្សាភ្ជាប់ទៅនឹងដៃគូចិននិងអន្តរជាតិ ដែលរួមមានអង្គការ Global Witness បន្ទាប់ពីដំណើរការពង្រាងដែលមានរយ:ពេលបីឆ្នាំ ដែលរួមទាំងការការពិគ្រោះយោបល់ជាសាធារណ:ផង ។

លោក Hines បានបន្ថែមថា ៖ “គោលការណ៍ណែនាំទាំងឡាយ ត្រូវតែត្រូវបានអនុម័តប្រកាន់យកដោយក្រុមហ៊ុនទាំងឡាយ ប្រសិនបើពួកគេនឹងបង្កឲ្យមានផលប៉ះពាល់ពិតប្រាកដណាមួយ ។ ប្រសិបបើពួកគេមិនអនុវត្តវាទេ ក្រុមហ៊ុនប្រថុយប្រថាននឹងការណ៍ដែលថា ឈានមិនទាន់តាមបទដ្ឋានដ៏ខ្លាំងក្លានៃឧស្សាហកម្មដែលកំពុងតែរីកចម្រើនឡើងឡើយ”។

ការស៊ើបអង្កេតនានារបស់អង្គការ Global Witness បានវែកមុខហានិភ័យផ្នែកបរិស្ថាន ផ្នែកសង្គម និងផ្នែកហិរញ្ញវត្ថុច្រើន គួរឲ្យកត់សម្គាល់ដែលជាប់ទាក់ទងនឹងការបន្តពង្រីកជាទ្រង់ទ្រាយសកលលោកនៃតម្រូវការកៅស៊ូធម្មជាតិ ។ ការវែកមុខឲ្យឃើញជា សាធារណ:របស់យើងចំពោះក្រុមហ៊ុនកៅស៊ូយក្សដូចជា Hoang Anh Gia Lai និង Vietnam Rubber Group បានស្តែងឲ្យឃើញយ៉ាងលេចធ្លោនូវផលវិបាកនានាដែលក្រុមហ៊ុននឹងត្រូវប្រឈមមុខនៅពេលពួកគេមិនធ្វើការឆែកពិនិត្យនានាដើម្បីធានាឲ្យបានថា ចំការដែលត្រូវបានលៃទុកដោយរដ្ឋាភិបាលដើរស្របតាមច្បាប់ឬទេនោះ ។

ឧស្សាហកម្មកៅស៊ូបានស្តែងឲ្យឃើញថាអតិថិជនសំខាន់ៗនៃដំណាំកៅស៊ូធម្មជាតិ បានណែនាំដាក់បញ្ចូលគោលការណ៍ទទួលទិញបន្តពី

ប្រភពផ្គត់ផ្គង់កៅស៊ូដើម្បីទទួលបាននូវចរន្តផ្គត់ផ្គង់ចីរភាពនៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ដែលបានបង្ហាញឲ្យឃើញពីការបត់ចង្កូតមួយយ៉ាងគំហុក នៅក្នុងឧស្សាហកម្មដែលភាគច្រើនមិនត្រូវបានធ្វើនិយ័តកម្មឲ្យបានមាំទាំឡើយ[2]។ បន្ថែមពីនេះ ប្រតិបត្តិកំពូលរបស់ក្រុមហ៊ុន ពេលនេះ អាចត្រូវបានដាក់ឲ្យទទួលខុសត្រូវក្នុងសកម្មភាពឧក្រិដ្ឋនៅក្រោមច្បាប់អន្តរជាតិសម្រាប់បទឧក្រិដ្ឋដែលផ្សារភ្ជាប់ទៅនឹងការដណ្តើមដីធ្លី និងការបំផ្លាញឲ្យហិនហោចដល់បរិស្ថាន ក្រោយដំណើរវិវឌ្ឍន៍នៅក្រោមតុលាការបទឧក្រិដ្ឋអន្តរជាតិ។[3]

អង្គការ Global Witness កំពុងតែលើកទឹកចិត្តជម្រុញសហគមន៍ទាំងឡាយនៅទូទាំងអាស៊ីអាគ្នេយ៍ឲ្យត្រួតពិនិត្យតាមដានប្រតិបត្តិការទាំងឡាយរបស់ក្រុមហ៊ុនកៅស៊ូ និងប្រើប្រាស់គោលការណ៍ណែនាំ CCCMC នៅក្នុងការចូលប្រឡូកពាក់ព័ន្ធរបស់ពួកគេជាមួយក្រុមហ៊ុននានា ។

លោក Hines មានប្រសាសន៍ថា ៖ “CCCMC នឹងត្រូវបានអបអរសាទរសម្រាប់ការបង្កើតគោលការណ៍ណែនាំទាំងឡាយរបស់ពួកគេ ដែលតំណាងឲ្យជំហានវិធានការណ៍មួយគួរជាទីកត់សម្គាល់ឆ្ពោះទៅកាន់ការលុបបំបាត់ ការចាប់ដណ្តើមយកដីធ្លី និងការកាប់បំផ្លាញព្រៃឈើ ពីសំណាក់បណ្តាញក្រុមហ៊ុនដែលជាខ្សែសង្វាក់ផ្គត់ផ្គង់ទាំងឡាយនោះ ។ អ្វីដែលសម្ខាន់ក្នុងពេលប្តុប្បន្ននេះ គឺថា ក្រុមហ៊ុនកៅស៊ូចិនទាំងឡាយ អនុវត្តគោលការបង់ដ្ឋានយ៉ាងខ្ជាប់ខ្ជួន និងញ៉ាំងឲ្យក្រុមហ៊ុននានាចង់ធ្វើដូចខ្លួនដែរ” ។

**/ចប់**

**សម្រាប់ព័ត៌មានបន្ថែមនិងការសម្ភាសន៍ សូមទាក់ទង:**

George Boden, មេក្រុមការងារដីធ្លី gboden@globalwitness.org
T: +44 (0)207 492 5899, M:+44 (0)7808 767 134

Ali Hines, ក្រុមការងារដីធ្លី ahines@globalwitness.org
T: +44 (0) 207 492 5831, M: +44 (0) 7738 712955

**កំណត់សម្គាល់ជូនចំពោះនិពន្ធនាយក ៖**

1. **ធាតុសំខាន់នៃគោលការណ៍ណែនាំ រួមមាន ៖**
   - គោរពនិងការពារសិទ្ធិសហគមន៍ក្នុងតំបន់ទាក់ទងនឹងដីធ្លីនិងធនធានធម្មជាតិដទៃទៀត ។ ការនេះ រួមមានសិទ្ធិរបស់ជនជាតិដើមភាគតិចចំពោះការយល់ព្រមប្រកបដោយសេរីភាពជាមុន និងដោយបានទទួលការពន្យល់ច្បាស់ ។
   - អនុវត្តនូវការវាយតម្លៃជាន់ប្រមាណពីផលប៉ះទង្គិចបរិស្ថាននិងសង្គមដ៏ទូលំទូលាយគ្រប់ជ្រុងជ្រោយដើម្បីធានាឲ្យបានថា ផលប៉ះទង្គិចដែលបង្កទុក្ខទោសត្រូវបានកាត់បន្ថយសម្រាលឲ្យស្រាលតិចតួចប៉ុណ្ណោះ ។
   - ការប្រកាន់ការអនុម័តយកនូវគោលនយោបាយ ‘ការកាប់បំផ្លាញព្រៃឈើកម្រិតសូន្យ’ ដើម្បីការពារ ជីវៈចម្រុះ និងព្រៃឈើដែលនៅល្អដែលមិនរងការប៉ះពាល់ ។
   - ផ្តួចផ្តើមបង្កើតនូវយន្តការបណ្តឹងសារទុក្ខសហគមន៍ និងធានាឲ្យបានថាសហគមន៍ត្រូវបានសងជំងឺចិត្តដោយពេញលេញសម្រាប់ការបាត់បង់នូវធនធាននានា ។

2. ក្រុមហ៊ុនយក្សសម្បកកង់ Michelin បានចាប់ផ្តើមដំណើរការនូវគោលនយោបាយការប្រើប្រាស់ប្រភពកៅស៊ូធម្មជាតិប្រកបដោយចីរភាពថ្មី (Sustainable Natural Rubber Sourcing Policy) ក្នុងឆ្នាំ 2015 ដែលបានចងភ្ជាប់ក្រុមហ៊ុនទៅនឹងការប្តេជ្ញាចិត្តចំពោះការកាប់បំផ្លាញព្រៃឈើកម្រិតសូន្យ និងការការពារសិទ្ធិដីធ្លីនៅក្នុងរាល់គ្រប់ប្រតិបត្តិការរបស់ខ្លួន ។ ក្រុមហ៊ុនបានផ្តោតគោលដៅធ្វើផែនទី 100% នៃក្រុមហ៊ុនផ្គត់ផ្គង់របស់ខ្លួនដើម្បីធានាឲ្យបាននូវភាពអាចតាមដានបានទាំងស្រុងនៃខ្សែសង្វាក់នៃការផ្គត់ផ្គង់របស់ខ្លួន ។ ក្រុមហ៊ុនទាំងឡាយ ដែលរួមមានក្រុមហ៊ុនជាច្រើនដែលមានមូលដ្ឋានក្នុងប្រទេសចិន ដែលខកខានមិនបានប្រកាន់អនុវត្តនូវគោលការណ៍ណែនាំថ្មី គឺប្រថុយនឹងការប្រឈមមុខនឹងការបាត់បង់អាជីវកម្មពីអ្នកដើរតួនាទីថ្នាក់អន្តរជាតិធំៗ ។

3. វិធានការណ៍ថ្មីៗដោយរដ្ឋអជ្ញានៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) ដើម្បីពង្រីកការផ្តោតការយកចិត្តទុកដាក់របស់ខ្លួន បានផ្តល់ជាសញ្ញាអំពីការផ្លាស់ប្តូរនូវព្រឹត្តិការណ៍សំខាន់គួរកត់សម្គាល់ នៅក្នុងប្រវត្តិសាស្ត្រ នៃយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ ។ ក្នុងប្រទេសកម្ពុជា ការដណ្តើមដីធ្លីបានកើតមានឡើងនៅក្នុងទ្រង់ទ្រាយដូចបែបនោះ និងជាប្រព័ន្ធយ៉ាងខ្លាំងក្លាដែល ICC កំពុងតែពិចារណាធ្វើការស៊ើបអង្កេតទៅលើសកម្មភាពនោះដោយចាត់ទុកថាជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ។ ប្រតិបត្តិករកំពូលរបស់ក្រុមហ៊ុននានា នៅពេលនេះ អាចត្រូវបានគេដាក់ឲ្យទទួលខុសត្រូវជាលក្ខណៈ បទឧក្រិដ្ឋនៅក្រោមច្បាប់អន្តរជាតិពីបទឧក្រិដ្ឋទាក់ទងនឹងការដណ្តើមដីធ្លី និងការបំផ្លាញបរិស្ថាន ។ កៅស៊ូ គឺជាធាតុរុញច្រានមួយក្នុងចំណោមធាតុរុញច្រានដ៏សំខាន់នានានៃការដណ្តើមយកដីធ្លីនៅក្នុងប្រទេសនានាដូចជាកម្ពុជានេះ ។